ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មាន
## របស់ក្រសួងសុខាភិបាលស្តីពីលទ្ធផលតេស្តជាផ្លូវការ នៃភាពអវិជ្ជមានវីរុសកូរ៉ូណាថ្មី (COVID-19) លើអ្នកទេសចរណ៍សមុទ្រនាវាមាន ឈ្មោះថា វេស្ទើដាម (Westerdam) ដែលជាកម្មសិទ្ធិរបស់ ហូឡង់-អាមេរិកា ឡាញ (Holland-America Line) នៅខេត្តព្រះសីហនុ

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណៈជនទាំងអស់ឲ្យបានជ្រាបថា ការធ្វើតេស្តដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាលើវត្ថុវិភាគរបស់អ្នកមានបញ្ហាសុខភាពចំនួន ២០ នាក់ ដែលនៅលើនាវាទេសចរវេស្ទើដាម ដែលចូលសំចតនៅកំពង់ផែខេត្តព្រះសីហនុ បានបង្ហាញលទ្ធផលអវិជ្ជមានវីរុសកូរ៉ូណាថ្មី(COVID-19)ហើយស្ថានភាពរបស់ពួកគាត់នៅពេលនេះមិនមានបញ្ហាធំដុំគួរឲ្យបារម្ភឡើយ ។

គួរកត់សម្គាល់ថាក្រោយពីនាវាទេសចរប្រភេទខាងលើនេះ មិនបានទទួលការអនុញ្ញាតឲ្យចូលចតចំនួន៥ប្រទេសហើយនោះ ក្នុងសណ្តានចិត្តមនុស្សធម៌ពិតប្រាកដ និងការសម្រេចដ៏មហិមាប្រកបដោយគតិបណ្ឌិត និងភាពឈ្លៀសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាវាខាងលើនេះ បានចូលចតនៅកំពង់ផែខេត្តព្រះសីហនុ នៅវេលាម៉ោងប្រហែលជា៧ព្រឹកនាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។ ប្រហែលជាម៉ោង៨:០០ព្រឹកនៃថ្ងៃដដែល ភ្លាមៗនោះ ក្រុមការងារឆ្លើយតបបន្ទាន់ថ្នាក់ជាតិនៃក្រសួងសុខាភិបាល និងថ្នាក់ខេត្ត នៃមន្ទីរសុខាភិបាលខេត្តព្រះសីហនុ បានធ្វើដំណើរតាមកាណូតទៅឡើងលើនាវាទេសចរណ៍ នេះដែលស្ថិតនៅចំណុចសូន្យ (Zero point) លើផ្ទៃសមុទ្រឆ្ងាយពីកំពង់ផែខេត្តព្រះសីហនុ ដើម្បីធ្វើការពិនិត្យសុខភាពតាមវិធានការចត្តាឡីស័កនៃច្បាប់សុខភាពអន្តរជាតិឆ្នាំ២០០៥ (IHR-2005) ដែលមានអ្នកដំណើរចម្រុះចំនួន ៤១ សញ្ជាតិ ដែលមានចំនួន១,៤៥៥នាក់ និងបុគ្គលិកធ្វើការរួមទាំងនាវិកចំនួន ៨០២នាក់ សរុបចំនួនទាំងអស់មាន ២,២៥៧ នាក់នៅលើកប៉ាល់នោះ ។ ក្រោយពីធ្វើការសហការជាមួយក្រុមគ្រូពេទ្យរបស់នាវា និងការពិនិត្យដោយហ្មត់ចត់របស់ក្រុមគ្រូពេទ្យ យើងបានរកឃើញមានអ្នកទេសចរដែលមានបញ្ហាសុខភាពចំនួន២០នាក់ មានអាយុពី ២២ ដល់ ៧៧ ឆ្នាំ (ស្រី៖ ៩ និង ប្រុស៖ ១១) ដែលមាន៧សញ្ជាតិ( អាមេរិក: ៧ ឥណ្ឌូណេស៊ី: ៤; ហ្វីលីពីន: ៣ ; ហូឡង់: ២ ; កាណាដា: ២ ; បែលហ្ស៊ិក: ១ ; និងអង់គ្លេស: ១) ។

បន្ទាប់ពីការពិភាក្សាបច្ចេកទេស ក្នុងកិច្ចការពារហេតុការណ៍ដែលអាចកើតមានឡើងជាយថាហេតុនិងដើម្បីឲ្យមានភាពជាក់លាក់នោះ **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល

បានសម្រេចឲ្យក្រុមការងារឆ្លើយតបបន្ទាន់របស់កម្ពុជាយកសំណាកវត្ថុវិភាគទាំង២០នាក់ រួចបញ្ជូនទៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាតាមយន្តហោះអេលីកុបទ័រចំនួន២ជើង (ជើងទី១ ចំនួន ១៤ សំណាក និងជើងទី២ ចំនួន ៦ សំណាក)។ លទ្ធផលជាផ្លូវការបានបង្ហាញអវិជ្ជមានវីរុសកូរ៉ូណាថ្មី (COVID-19) នៅវេលាម៉ោង៨:៣០យប់នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ។

ក្នុងពេលរង់ចាំលទ្ធផលវិភាគពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អ្នកដំណើរទាំងអស់រួមទាំងបុគ្គលិកនិងនាវិកនៃកប៉ាល់ខ្នាតធំប្រភេទនេះ មិនត្រូវបានអនុញ្ញាតឲ្យឡើងគោកឡើយ ។ រីឯអ្នកមានអាការៈសុខភាពទាំង២០នាក់នោះ ក៏តម្រូវឲ្យនៅក្នុងបន្ទប់ដាច់ដោយឡែកៗដែលមាននៅលើនាវានោះស្រាប់ ។ ប្រតិបត្តិការផ្នែកសុខាភិបាលខាងលើប្រព្រឹត្តទៅបានជោគជ័យ ដោយមានការដឹកនាំចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងការគ្រប់គ្រងអនុវត្តន៍ យ៉ាងយកចិត្តទុកដាក់បំផុតពីសំណាក់ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ការយកចិត្តទុកដាក់ក្នុងការផ្តល់អន្តរាគមន៍ដឹកជញ្ជូនវត្ថុវិភាគដោយប្រើយន្តហោះអេលីកុបទ័រពីសំណាក់ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** មេបញ្ជាការរងកងយុទ្ធពលខេមរភូមិន្ទ អមដំណើរដោយលោកជំទាវវេជ្ជបណ្ឌិត **ឱ វណ្ណឌីន** រដ្ឋលេខាធិការនិងជាអ្នកនាំពាក្យក្រសួងសុខាភិបាល លោកស្រី លឹម សាមាន ប្រធានមន្ទីរសុខាភិបាលខេត្តព្រះសីហនុ ព្រមទាំងថ្នាក់ដឹកនាំ បុគ្គលិក ក្រុមឆ្លើយតបបន្ទាន់និងក្រុមគ្រូពេទ្យថ្នាក់ជាតិ ថ្នាក់ខេត្ត និងផ្នែកពាក់ព័ន្ធផ្សេងៗទៀត ជាពិសេសដោយមានកិច្ចសហការដ៏ល្អបំផុតពីសំណាក់ឯកឧត្តម **គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងឯកឧត្តម **លូ គឹមឈុន** អគ្គនាយកកំពង់ផែស្វយ័តខេត្តព្រះសីហនុ និងបុគ្គលិកកំពង់ផែ និងកងកម្លាំងការពារមួយចំនួនផងដែរ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមសាធារណៈជន មេត្តាជ្រាប ហើយក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណៈជន អំពីការវិវត្តនៃបញ្ហាសុខភាពតាមគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលគេហទំព័រ នេះមានសំភារៈអប់រំសុខភាពដែលអាចទាញយកមកមើលបាននិងហ្វេសប៊ុកនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅខេត្តព្រះសីហនុ, ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២០

ហត្ថលេខា

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា